ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១១ សហវ.អគ.ហ.អតន

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបង់ចំណូលមិនមែនសារពើពន្ធ
# តាមប្រព័ន្ធទូទាត់អេឡិចត្រូនិក នៅរដ្ឋបាលថ្នាក់ជាតិ ជំហានទី១

អនុលោមតាមសារាចរ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក (e-Payment) សម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធ និងអនុវត្តតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំប្រកាសលេខ១៦៦ សហវ.ប្រក អរតន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃចំណូលមិនមែនសារពើពន្ធ និងប្រកាសលេខ៣៥០ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ ៩ ស្តីពីចំណូលពីប្រតិបត្តិកាដោះដូរ និងលេខ ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ តាមមូលដ្ឋានចំណូលបង្គរ ដោយត្រូវកត់ត្រាចំណូលបង្គរ និងចំណូលពន្យារ។ ដើម្បីអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងដាក់ឱ្យដំណើរការមុខងារកត់ត្រាចំណូលបង្គរ និងចំណូលពន្យារនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) សម្រាប់ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ ដែលត្រូវអនុវត្តប្រព័ន្ធនេះ លើមុខសញ្ញាចំណូលពីកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ។

ក្រសួង ស្ថាប័ន និងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ ដែលនឹងត្រូវអនុវត្ត នៅជំហានទី១ មានចំនួន ១០ក្រសួង ស្ថាប័ន រួមមាន៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព្រះបរមរាជវាំង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងការពារជាតិ ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងយុត្តិធម៌ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ។ ការដាក់ឱ្យអនុវត្តនៅជំហានទី១នេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- រដ្ឋបាលកណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្តចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៤ តទៅ

២- រដ្ឋបាលកណ្តាល នៃក្រសួង ស្ថាប័ន ៩ផ្សេងទៀត រួមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត នឹងអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ដើម្បីដាក់ឱ្យអនុវត្តមុខងារថ្មីនេះបានរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជម្រាបជូនដំណឹងដល់ធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាបថា៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានតម្រូវឱ្យក្រសួង ស្ថាប័ន និង មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ក្រោមឱវាទខាងលើ ត្រូវអនុវត្តការបង់ចំណូលមិនមែន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

សារពើពន្ធតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក តាមរយៈកម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ តាមរយៈកម្មវិធីលើទូរសព្ទដៃឆ្លាតវៃរបស់ធនាគារពាណិជ្ជដៃគូ មានជាអាទិ៍៖ ធនាគារ អេស៊ីលីដា ភីអ៊ិលស៊ី ធនាគារ កាណាឌីយ៉ា ក.អ និង ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់។

ចំពោះនីតិវិធីដទៃទៀតក្រៅពីនីតិវិធីបន្ថែមខាងលើនេះ ធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ត្រូវអនុវត្តតាមនីតិវិធីបច្ចុប្បន្នដែលនៅជាធរមាន។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ជ្រាប និងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

ថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន៖</u>**
-ធនាគារពាណិជ្ជដៃគូ
-គ្រឹះស្ថានហិរញ្ញវត្ថុដៃគូ
"ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ